# Living the Lotus 11

2023

VOL. 218

*Buddhism in Everyday Life*




*Chihkan Tower, a historical building in Tainan, Taiwan / Shutterstock*

Rissho Kosei-kai of Tainan


**Living the Lotus**
**Vol. 219 (November 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្ស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្ស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្ស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# ចូរកុំបីត្អូញត្អែរពេក

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## នៅពេលដែលប្រាជ្ញា（知）ឈឺ（「疒」）វាក៏ត្អូញត្អែរ,ថ្ងូរឬរអ៊ូ「痴」

រដូវក្តៅឆ្នាំនេះក្តៅដល់ទៅលំដាប់គ្រោះធម្មជាតិ។តែទោះជាមិនក្តៅដល់ទៅលំដាប់នេះក៏ដោយក៏មនុស្សយើងឱ្យតែដល់រដូវក្តៅ ហាមាត់មួយម៉ាត់ណាក៏រអ៊ូថាក្តៅដែរ រួចបើខែរងាវិញក៏ស្រែកថាតែរងា ៗ។ជាធម្មតា យើងដឹងហើយថា ការរអ៊ូចំពោះអ្វីដែលបង្កដោយធម្មជាតិឬក៏ជាព្រឹត្តិការណ៍នាអតីតកាលដែលកន្លងបាត់ទៅទោះជារអ៊ូទៅក៏គ្មានបានលទ្ធផលអ្វីដែរ ហើយតែទោះជាដឹងដូច្នេះក្តីក៏មនុស្សនៅតែរអ៊ូ។ការរអ៊ូចំពោះអ្វីៗដែលគ្មានបានលទ្ធផលអ្វីមកវិញនេះគេហៅថា “ត្អូញត្អែរ”។

ចុះអ្នកទាំងអស់គ្នាវិញនៅពេលដែលឮពាក្យថារអ៊ូទៅក៏គ្មានបានលទ្ធផលអ្វីដែរ តើនឹកទៅដល់អ្វី？

ខ្ញុំព្រះករុណាអាត្មាភាពឱ្យតែឮគេរអ៊ូម្តងៗចេះតែនឹកភ្នកជាពិសេសដល់អក្សរកាន់ជីចិនគឺអក្សរ「痴」ដែលមានន័យថាប្រាជ្ញាមានជម្ងឺ។「痴」ប្រាជ្ញាមានជម្ងឺនេះវាផ្គុំឡើងដោយអក្សរ「知」មានន័យថាប្រាជ្ញានិងអក្សរ「疒」មានន័យថាជម្ងឺ។ពោលគឺថាប្រាជ្ញានោះវាឈឺ។គួរឱ្យចាប់អារម្មណ៍ណាស់។ប្រាជ្ញាគឺជាភាពឆ្លាតវៃសម្រាប់យល់ដឹងនិងវិនិច្ឆ័យអ្វីមួយហើយចំណេះដឹង(知識)និងភាពឆ្លាតវៃ(知性)ដែល

សម្រាប់ទ្រទ្រង់វាសុទ្ធតែជាពាក្យដែលផ្គុំជាមួយនឹងអក្សរ「知」（ប្រាជ្ញា）។គឺថានៅពេលដែលពួកនេះមានជម្ងឺវាត្អូញត្អែរឬថ្ងូរឬរអ៊ូ។ក៏ប៉ុន្តែមនុស្សមានបញ្ញាដែលសម្រាប់ឱ្យគេអាចគិតមុននឹងធ្វើអ្វីមួយ។បណ្ឌិតរូបវិទ្យាលោកសាជី ហារីអូ បានសរសេរថា មនុស្សគឺជាអត្ថិភាពចម្លែក។គេកើតឡើងដោយវត្ថុធាតុដែលមានធាតុផ្សំអ៊ីដ្រូហ្សែន និងការបោនដូចតែនឹងចក្រវាលដែរ តែគេមិនមែនជាវត្ថុដូចវត្ថុធាតុទេគេរស់នៅដោយចេះគិត រួចទើបធ្វើរួចហើយមានសមានចិត្តចំពោះមនុស្សគ្នាឯងហើយជួយគ្នាទៅវិញទៅមក។ម្យ៉ាងទៀតមនុស្សមានសមត្ថភាពអាចគិតពី

អនាគតកាលព្រមចេះស្រមៃពីចិត្តអ្នកដទៃដោយសារតែគេមានបេះដូង។

ក៏ប៉ុន្តែយើងទាំងឡាយជាមនុស្ស ជាមួយនឹងបេះដូងដដែលហ្នឹងបង្កើតនូវតណ្ហានិងកំហឹងដោយភាពអាត្មានិយម ហើយប្រព្រឹត្តនូវអំពើលីលាដដែលៗបង្កទុក្ខដល់អ្នកដទៃ។ពោលគឺថាយើងបានត្រូវជម្ងឺប្រាជ្ញាដ៏លីលាវាចូលញាំញី។ដើម្បីកុំឱ្យតណ្ហានិងកំហឹងដោយភាពអាត្មានិយមនេះវាអាចបំបោលដូចសេះដាច់បង្ហៀរបានតើត្រូវធ្វើដូចម្ដេច?ហើយដើម្បីនឹងព្យាបាលជម្ងឺប្រាជ្ញាដ៏លីលាតើត្រូវធ្វើដូចម្ដេច?

## ស្ដាប់ពាក្យដំអូញដំអែររបស់អ្នកដទៃ

ចូរយើងរំលឹកឡើងវិញនូវពាក្យរបស់រូបវិទ្យាវិទូ សាជី ហារីអូជាថ្មី។បំណាច់នឹងបានជាកើតមក ជាមនុស្ស មានសមានចិត្តចំពោះមនុស្សគ្នាឯងហើយជួយគ្នាទៅវិញទៅមកហើយមានសមត្ថភាពអាច ស្រមើស្រមៃគិតពីអនាគតកាលព្រមទាំងពីចិត្ត អ្នកដទៃបានហើយគួរតែធ្វើឱ្យសមត្ថភាពនេះ មានប្រយោជន៍។

នៅពេលដែលគំនិតបែបអាត្មានិយមវាពន្លយ ក្បាលចេញមក យើងតោងតែមើលអ្វីៗពីគ្រប់ជ្រុងជ្រោយ មានសមានចិត្តដោយស្រមើស្រមៃ គិតទៅចិត្តរបស់អ្នកដទៃ ឬក៏គិតថាជម្ងឺប្រាជ្ញានេះបង្រៀនយើងនូវទស្សនៈចំណង ដូចព្រះ ធម៌និព្វានបានបង្ហាញស្រាប់គឺថាយើងទាំងឡាយសុទ្ធតែបានពង្រស់ឱ្យមានជីវិតរស់នៅដោយអ្វីៗទាំងអស់។ពេលគិតបែបនេះហើយយើងក៏កើតចិត្តដឹងគុណនៅក្នុងជីវភាពរស់នៅ ហើយពាក្យដំអូញដំអែរក៏នឹងចុះថយ។

នៅពេលដែលយើងគិតពីពាក្យចំណង មានការស្រាវជ្រាវមួយរកឃើញថា នៅក្នុងគ្រួសារប្រសិ នបើឪពុកម្ដាយគិតតែពីត្អូញត្អែរ ឬក៏និយាយអាក្រក់ពីអ្នកដទៃ កូនៗក៏នឹងទទួលឥទ្ធិពលមិនល្អហើយវាចូលចិត្តតែរអ៊ូរទាំ។

តើយើងចង់បានចំណងដែលបង្កឱ្យអ្នកជុំវិញយើងគេត្អូញត្អែរអ៊ូរទាំ ឬចង់បានចំណងដែលបំបើកភ្នែកបញ្ញា?យោលទៅតាមការដាក់ចិត្តរបស់យើងអ្វីៗក៏នឹងប្រែប្រួលទៅតាមនោះ។ក៏ប៉ុន្តែក៏មិនមែនជាបំរាមហាមមិនឱ្យត្អូញត្អែរសោះដែរ។បើមិនត្អូញត្អែរសោះក៏ថប់ដង្ហើម។ជាការពិតថាគេមិនត្រូវឱ្យតណ្ហានិងកំហឹងមកគ្រប់គ្រងខ្លួនឯងទេក៏ប៉ុន្តែជួនកាលក៏ត្រូវការឱ្យមនុស្សថ្ងូរឬត្អូញត្អែរនៅពេលដែលទ័លប្រាជ្ញឬឈឺចាប់ពេកដែរ។

សម្រេចសម្រួមទៅត្រូវតែដឹងខ្លួនថាបើនិយាយទៅក៏គ្មានលទ្ធផលដដែលឈប់រវល់វាហើយគិតវិជ្ជមានរួចហើយក៏ចាប់ផ្ដើមអ្វីៗពីចំណុចសូន្យដោយទឹកចិត្តថ្មីស្រឡាងមួយទៀត។ម្យ៉ាងទៀតយើងគួរតែធ្វើជាអ្នកទទួលស្ដាប់ពាក្យដំអូញដំអែរបស់អ្នកដទៃជាការប្រសើរ។មានអ្នកខ្លះនិយាយថាគ្នាធុញទ្រាន់នឹងស្ដាប់ពាក្យដំអូញដំអែរណាស់រើយ។ជាការពិតណាស់ក៏ប៉ុន្តែចូរយើងមានសមានចិត្តស្ដាប់ពាក្យសារស័ព្ទពីទុក្ខសោករបស់គេដើម្បីឱ្យគេបារចេញពីទ្រូងឱ្យអស់នូវទុក្ខសោកកង្វល់។ពេលដែលយើងទាំងអស់គ្នាពួតកម្លាំងគ្នារាវរកច្រកចេញដែលជាបេះដូងបញ្ញា ជាលទ្ធផលយើងនឹងបានលូតលាស់ទាំងសុខភាពផ្លូវកាយនិងចិត្ត ព្រមទាំងការលូតលាស់ជាមនុស្សទាំងអស់គ្នា។

『ទស្សនាវត្ដីកូសេ』 លេខខែវិច្ឆិកាឆ្នាំ២០២៣



# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




| Information about local Dharma centers | facebook | twitter |
| --- | --- | --- |

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp